ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
# ពោធិ៍កន្ទ្រីសែនជ័យ
# រយៈពេល៣ឆ្នាំ (២០១៧-២០១៩)

ឈ្មោះសហគមន៍នេសាទ ៖ ពោធិ៍កន្ទ្រីសែនជ័យ

ភូមិ ៖ ពោធិ៍,សំរោង,ពាមទន្លា,ថ្មី,ដំណាក់កកោះ និងភូមិកំពង់បាចិន

ឃុំ ៖ ពោធិ៍

ស្រុក ៖ កំពង់លែង

ខេត្ត ៖ កំពង់ឆ្នាំង

## មាតិកា

## ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

**១- ស្ថានភាពទូទៅ**

**២- អំពីប្រជាសាស្ត្រ**

ក- ប្រជាពលរដ្ឋ

ខ- មុខរបរ

**៣- កន្លែងនេសាទសហគមន៍ និងធនធានដែលមាននៅក្នុងកន្លែងនេសាទសហគមន៍**

ក- ទីតាំង

ខ- ដែននេសាទ

គ- តំបន់ដែលមានលទ្ធភាពបង្កើតកន្លែងអភិរក្ស

ឃ- ធនធានជលផល

**៤- ការធ្វើនេសាទ**

ក- អ្នកនេសាទ

ខ- ឧបករណ៍នេសាទ

គ- ការប៉ាន់ប្រមាណផលចាប់ប្រចាំឆ្នាំ

**៥- ផែនការគ្រប់គ្រងសហគមន៍នេសាទ**

ក- ទស្សនៈវិស័យ

ខ- គោលបំណង

គ- ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

គ១- ផែនការប្រើប្រាស់ឧបករណ៍នេសាទ

គ២- ផែនការកែលម្អដែននេសាទ

គ៣- ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស

គ៤- ផែនការគ្រប់គ្រងព្រៃលិចទឹក

គ៥- ផែនការទប់ស្កាត់បទល្មើសនេសាទ

គ៦- ផែនការប្រជុំប្រចាំខែ និងសម្ភារៈអនុវត្តការងាររបស់គណៈកម្មការសហគមន៍នេសាទ

គ៧- ផែនការផ្សព្វផ្សាយនិងបណ្តុះបណ្តាល

គ៨- ផែនការបង្កើតមុខរបរសមាជិកក្នុងសហគមន៍នេសាទ

គ៩- ផែនការបង្កើតកន្លែងទស្សនាកំសាន្តក្នុងសហគមន៍នេសាទ

គ១០- ផែនការបង្កើតក្រុមសន្សំឥណទានដើម្បីបង្កើនមុខរបរ

គ១១- ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទ

គ១២- ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍសហគមន៍

ឃ. ផែនការយុទ្ធសាស្ត្រ

- តារាងកម្មវិធីការងារ

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍

## ១ ស្ថានភាពទូទៅ

សហគមន៍នេសាទ **ស្វាយរំពារ** បានធ្វើមហាសន្និបាតកំណើតដំបូងរបស់សហគមន៍នេសាទ នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១០ និងបានធ្វើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០០៨ ។

សហគមន៍នេសាទ**ស្វាយរំពារ** មានទីតាំងស្ថិតនៅភូមិចំបក់ខ្ពស់ ក្នុង សំរោង ជើងគ្រួស តាឡាត់ ឃុំស្វាយរំពារ ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង។ ដែលមានសមាជិកសរុបចំនួន៨៩៤នាក់ ប្រុស៦៨៧នាក់ ស្រី២០៧នាក់ ក្នុងនោះ ចំនួនគ្រួសារសរុបមានចំនួន៦៨១គ្រួសារ។ មានគណៈកម្មការចំនួន១១នាក់ ស្រី០០នាក់។

កន្លងមកសហគមន៍នេសាទនេះ បានដំណើរការសកម្មភាពសំខាន់ៗ របស់ខ្លួនរួមមាន ៖

- បោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ
- រៀបចំបញ្ជីឈ្មោះសមាជិក និងគណៈកម្មការ សហគមន៍នេសាទ
- រៀបចំរចនាសម្ព័ន្ធគណៈកម្មការសហគមន៍នេសាទ
- រៀបចំលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ
- រៀបចំកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍
- កំណត់ព្រំប្រទល់កន្លែងនេសាទសហគមន៍និងធ្វើផែនទី
- ផ្សព្វផ្សាយច្បាប់ស្តីពីជលផល
- ទប់ស្កាត់បទល្មើសនេសាទក្នុងកន្លែងនេសាទសហគមន៍
- ការពារព្រៃលិចទឹក
- បង្កើតកន្លែងអភិរក្សត្រីមេពូជ
- ការពារកន្លែងអភិរក្សត្រីមេពូជ
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងធនធានជលផល
- ទស្សនៈកិច្ចសិក្សា
- ចូលរួមប្រជុំជាមួយភូមិ ឃុំ ស្រុក
- បង្កើតក្រុមមុខរបរ (ចិញ្ចឹមសត្វ ដាំបន្លែ ក្រុមសន្សំប្រាក់)
- ប្រមូលព័ត៌មានទូទៅសំរាប់ធ្វើផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍។

## ២ អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក. ប្រជាសាស្ត្រ

- ចំនួនប្រជាពលរដ្ឋសរុបក្នុងតំបន់មាន៣១៤១នាក់ ប្រុស១៥៣៧នាក់ ស្រី១៦០៤នាក់ ក្នុងនោះ មានចំនួន៦៨១គ្រួសារ ប្រជាពលរដ្ឋក្នុងតំបន់ជាអ្នកកាន់សាសនាព្រះពុទ្ធ100%។
- ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់
- អ្នកមិនចេះអក្សរចំនួន ៥៥០នាក់ ស្រី ១៧០នាក់
- កម្រិតថ្នាក់បឋមសិក្សាចំនួន៩៦៦ ស្រី ៤៣៩នាក់
- កម្រិតមធ្យមសិក្សាចំនួន៣៩៣ ស្រី ២៣៤នាក់

- កម្រិតឧត្តមសិក្សាចំនួន 	០០នាក់ 	ស្រី ០០ នាក់
- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមានចំនួន 	៨៥នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមានចំនួន 	១៦នាក់ 	ស្រី ០៥នាក់
- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមានចំនួន 	២៥នាក់ 	ស្រី ១៧នាក់
- ចំនួនកុមារកំព្រាក្នុងសហគមន៍នេសាទមានចំនួន 	០៦នាក់ 	ស្រី ០២នាក់
- ចំនួនអ្នកមានជំងឺរ៉ាំរ៉ៃក្នុងសហគមន៍នេសាទមាន 	២៥នាក់ 	ស្រី១៨នាក់។

**ខ. មុខរបរ**

មុខរបរសំខាន់ៗរបស់សមាជិកក្នុងសហគមន៍នេសាទនេះរួមមាន៖

- ធ្វើនេសាទចំនួន 	៤៣៦ គ្រួសារ
- ធ្វើស្រែចំនួន 	៤៨០ គ្រួសារ 	ទំហំ៣៨៥ ហិកតា
- ធ្វើវីវប្បកម្មចំនួន 	៤២០គ្រួសារ
- ចិញ្ចឹមត្រីក្នុងស្រះចំនួន 	០៤ គ្រួសារ 	ស្រះមានទំហំ ១២៣៨ម៉ែត្រការ៉េ
- ចិញ្ចឹមត្រីក្នុងបែរចំនួន 	៣៨ គ្រួសារ 	ស្រះមានទំហំ ២០៤ម៉ែត្រការ៉េ
- ដាំបន្លែចំនួន 	០៨ គ្រួសារ 	ស្រះមានទំហំ ២៣៥ម៉ែត្រការ៉េ
- ជាងផ្ទះចំនួន 	០៨ គ្រួសារ
- លក់ដូរចំនួន 	៣២ គ្រួសារ
- កម្មករ 	២៧ គ្រួសារ
- ប្រាក់ចំណូលជាមធ្យមក្នុង០១គ្រួសារ ប្រចាំឆ្នាំមានចំនួន ២៥០,០០០រៀល ។

## ៣ កន្លែងនេសាទសហគមន៍ និងធនធានដែលមាននៅក្នុងនេសាទសហគមន៍

**ក. ទីតាំង**

កន្លែងនេសាទសហគមន៍ ស្វាយរំពារ ត្រូវលុបចេញពីអតីតឡូត៍នេសាទ ដែននេសាទទឹកសាប ក្នុងខេត្តកំពង់ឆ្នាំង មានទំហំ១៧៦ហិកតា និងមានកំណត់និយាមកាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង ។

មានព្រំប្រទល់ ៖

- ខាងជើងទល់នឹងភូមិដំណាក់កកោះ
- ខាងត្បូងទល់នឹងកំពង់ចិន
- ខាងកើតទល់នឹងសំរិទ្ធជ័យ
- ខាងលិចទល់នឹងជើងក្រូស។

**ខ. ដែននេសាទ**

កន្លែងនេសាទសហគមន៍នេសាទពោធិ៍កន្ទ្រីសែនជ័យ មានបឹងចំនួន២៣បឹង ព្រែកចំនួន៦ព្រែក អូរឬប្រឡាយចំនួន ១៣ អូរ គឺ៖

| | | |
|---|---|---|
| បឹងនគរទ្វីប | ទំហំ ១១០០ម x ១៣០ម | នេសាទពេញមួយឆ្នាំ |
| បឹងពាន់តាកង | ទំហំ ៩០០ម x ៩០ម | នេសាទពេញមួយឆ្នាំ |

| | | |
|---|---|---|
| បឹងចក | ទំហំ ៨៥០០ម x ១២០ម | នេសាទពេញមួយឆ្នាំ |
| បឹងក្រាញ់ | ទំហំ ១២០ម x ១០០ម | នេសាទពេញមួយឆ្នាំ |
| បឹងបាយឡៅ | ទំហំ ១០០០ម x ២៦០០ម | នេសាទពេញមួយឆ្នាំ |
| បឹងវែង | ទំហំ ១៥០ម x ៥០ម | នេសាទពេញមួយឆ្នាំ |
| បឹងដំរីស្អុយ | ទំហំ ២៥០ម x ៨០ម | នេសាទពេញមួយឆ្នាំ |
| បឹងយួនអុច | ទំហំ ៣៥០ម x ១០០ម | នេសាទពេញមួយឆ្នាំ |
| បឹងតាសែត | ទំហំ ៧០ម x ៤០ម | នេសាទពេញមួយឆ្នាំ |
| បឹងទទឹងថ្ងៃ | ទំហំ ៥០០ម x ៥០ម | នេសាទពីខែ មេសា ដល់ ខែ ឧសភា |
| បឹងក្រចាប់ | ទំហំ ២០០ម x ៤០ម | នេសាទពីខែ មេសា ដល់ ខែ ឧសភា |
| បឹងបាក់អង្រុត | ទំហំ ១៥០ម x ១០០០ម | នេសាទពីខែ មេសា ដល់ ខែ ឧសភា |
| បឹងអន្ទិល | ទំហំ ២០០ម x ៥០ម | នេសាទពីខែ មេសា ដល់ ខែ ឧសភា |
| បឹងព្រលូងធំ | ទំហំ ១០០០ម x ២០០ម | នេសាទពីខែ មេសា ដល់ ខែ ឧសភា |
| បឹងផ្សារ | ទំហំ ១០០០ម x ៧០ម | នេសាទពីខែ មេសា ដល់ ខែ ឧសភា |
| បឹងបាយឡៅ | ទំហំ ៥០០ម x ៧០ម | នេសាទពីខែ កុម្ភៈ ដល់ ខែ ឧសភា |
| បឹងសាមស្រី | ទំហំ ៣០០ម x ១០០ម | នេសាទពីខែ កុម្ភៈ ដល់ ខែ ឧសភា |
| អាងព្រលូងតូច | ទំហំ១០០០ម x ៥០០ម | នេសាទពីខែ កុម្ភៈ ដល់ ខែ ឧសភា |
| ទំនប់អភិវឌ្ឍន៍អណ្តែង | ទំហំ ៧០០ម x ១៥០ម | នេសាទពីខែ កុម្ភៈ ដល់ ខែ ឧសភា |
| បឹងរាំង១ដើម | ទំហំ ៤០ម x ១៧០ម | នេសាទពីខែ កុម្ភៈ ដល់ ខែ មីនា |
| បឹងកន្ទ្រប | ទំហំ ៥០ម x ១២០ម | នេសាទពីខែ កុម្ភៈ ដល់ ខែ ឧសភា |
| បឹងខ្លាខាំគោ | ទំហំ ១២០ម x ៩០០ម | នេសាទពីខែ មករា ដល់ ខែ ឧសភា |
| បឹងសាច់ខ្មៅ | ទំហំ ៩០ម x ៩០០ម | នេសាទពីខែ កុម្ភៈ ដល់ ខែ ឧសភា |
| បឹងរលំតូច | ទំហំ៤០ម x ២៥០ម | នេសាទពីខែ មករា ដល់ ខែ មីនា |
| បឹងរលំធំពាក់កណ្តាល | ទំហំ ១០០ម x ៩០០ម | នេសាទពីខែ មករា ដល់ ខែ មេសា |
| បឹងប្រយ៉ាប | ទំហំ ៤០ម x ១០០០ម | នេសាទពីខែ មករា ដល់ ខែ ឧសភា |
| បឹងសត្វចងក | ទំហំ ៥០ម x ១៧០ម | នេសាទពីខែ មករា ដល់ ខែ ឧសភា |
| បឹងប្រឡាក់ក្របី | ទំហំ ៣០ម x ២០០ម | នេសាទពីខែ មករា ដល់ ខែ ឧសភា |
| បឹងថ្លុកតាគង់ | ទំហំ ៥០ម x ១៥០ម | នេសាទពីខែ មករា ដល់ ខែ ឧសភា |
| បឹងខ្សាច់ | ទំហំ ៥០ម x ៥០ម | នេសាទពីខែ មករា ដល់ ខែ ឧសភា |
| បឹងព្រែកក្រពើ | ទំហំ ៥០ម x ៥០ម | នេសាទពីខែ មករា ដល់ ខែ ឧសភា |
| បឹងផ្ទោល | ទំហំ ៤០ម x៧០ម | នេសាទពីខែ មករា ដល់ ខែ ឧសភា |
| បឹងផ្កាយ | ទំហំ ៤០ម x៧០ម | នេសាទពីខែ មករា ដល់ ខែ ឧសភា |
| បឹងខ្មៅ | ទំហំ ៤០ម x១០០ម | នេសាទពីខែ មករា ដល់ ខែ ឧសភា |
| ព្រែកសស្ទឹងសណ្តែក | មានទំហំ១០០ម x២៥ម | នេសាទពីខែ មិថុនា ដល់ ខែ មេសា |
| ព្រែកទួលស្វាដេក | មានទំហំ១២០០ម x៦០០ម | នេសាទពីខែ មិថុនា ដល់ ខែ មេសា |

អូរកោះគៀប មានទំហំ១០០ម x៤០ម នេសាទពីខែ មិថុនា ដល់ ខែ មេសា

អូរដៃឆ្លង មានទំហំ១២០០ម x៦ម នេសាទពីខែ មិថុនា ដល់ ខែ មេសា

ស្ពានកោះបូ មានទំហំ១២០០ម x៦ម នេសាទពេញមួយឆ្នាំ

**គ. តំបន់ដែលមានលទ្ធភាពបង្កើតកន្លែងអភិរក្ស**

ស្ពានកោះបូ មានទំហំ២០ម x ២០ម x **៧ម** ខែប្រាំងមានជម្រៅ៧ម

**ឃ. ធនធានជលផល**

- **ប្រភេទត្រី ៖**

ត្រីរ៉ស់ ត្រីឆ្តោរ ត្រីឆ្លាំង ត្រីកែស ត្រីក្អែក ត្រីកញ្ចុះ ត្រីលិញ ត្រីរៀល ត្រីក្រាញ់ ត្រីចង្វារ ត្រីផ្ទោង ត្រីស្លូញ ត្រីពោ ត្រីអាចម៍កុក ត្រីស្លឹកឫស្សី ត្រីកន្ត្រប់ ក្លាំងហាយ ត្រីខ្នាន់ ត្រីក្រឡង់ ត្រីសណ្តាយ ត្រីអណ្តែង ត្រីដំរី ត្រីតាអោន ត្រីក្រម៉ម ត្រីស្លាត ត្រីកំភ្លៀវ ត្រីខ្ទីង ត្រីអំពិលទុំ ត្រីគ្រុំ ត្រីផ្កាស្មៅ ត្រីឈ្វៀត ត្រីកញ្ជ្រូក ត្រីបណ្តូលអំពៅ ត្រីច្រកែង ត្រីកាហែ ត្រីក្រឹម ត្រីក្រឹមទន្សាយ ត្រីស្រកាក្ដាម ត្រីលលកសរ ត្រីឆ្អិន ត្រីបណ្តូលចេក ត្រីព្រលូង ត្រីកំពត ត្រីក្រពាត់ ត្រីក្រុស ត្រីកញ្ចាញ់ច្រាស ត្រីកំភ្លាញ ត្រីស្លាត ត្រីក្រាយ ត្រីអណ្តាតឆ្កែ កំពិស។

- **ប្រភេទវារីសត្វ ៖**

អណ្តើក ពស់ ខ្យងគូចស្រួច ខ្យងគូចទាល ក្តាម អន្ទង់ ខ្ចៅគូចស្រួច ខ្ចៅគូចទាល កង្កែប ឈ្លើង គ្រុំ គ្រុំចំពុះទាលៀស ។ល។

- **ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ ៖**

ដើមថ្លើមអណ្តើក ខ្លបយក្ស(អូយយ៉ាស់/បន្លាយយួន) រាំង ប្របួយមេ ប្របួយឈ្មោល ស្បាត ភ្នំភ្លើង អញ្ចាញ ត្នូ ស្នែងក្របី ធ្មេញត្រីញី ទៀនព្រៃ ត្រស់ ថ្វាង ខ្លាយមាន់ វល្លិប្រេង វល្លិទឹកដោះ វល្លិត្រដិត វល្លិដោះគន់ វល្លិត្រី វល្លិត្អើក អំពាក់ទឹក ស្លាបទា កន្ទាំងហៃ ស្នោ ស្លត បន្លាឃ្លេ ថ្វាន់ ស្នួលទឹក ច្រកែង ប្រផេញ ផ្តៅ ភ្នែកព្រាប វល្លិអណ្តាតត្រកួត ក្រចាប់ សារាយសាប កំប្លោក ចកតូច ចកធំ កំពីងពួយស កំពីងពួយក្រហម ត្រកួន ព្រលិតអាចម៍មាន់ ព្រលិតដូង រំចង់ ស្គន់អំបោះ ត្រាវអណ្តែត ស្មៅអន្ទក់ទឹក ចំប្លង កក់ជ្រុង កក់ក្តាម ឈូក ចន្ទល់ភ្នំ(វល្លិថ្កាល់ត្រី) កញ្ឆែត ស្មៅថ្នក់ទឹក ។ល។

## ៤. ការធ្វើនេសាទ

**ក. អ្នកនេសាទ ៖**

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន៥៨នាក់ ស្រី០៨នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទនៅក្នុងសហគមន៍មាន

- ចំនួន៥០នាក់ ស្រី០៥នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍មានចំនួន៨០នាក់ ស្រី៣០នាក់។

**ខ. ឧបករណ៍នេសាទ ៖**

- ឧបករណ៍នេសាទនិងទូកកាណូតរបស់សមាជិកសហគមន៍នេសាទ ៖

| ប្រភេទ ឧបករណ៍ | ឯកតា | ចំនួន គ្រួសារ | ចំនួនឧបករណ៍ នេសាទ (ជាមធ្យម/គ្រួសារ) | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| មងរាយ | ដៃ(១ដៃ=៨០ម) | ៤៥ | ៥ដៃ/គ្រួសារ=៤០០ម | ១៨០០០ម | ពេញមួយឆ្នាំ |
| លបឫស្សី | គ្រឿង | ៥ | ៥០គ្រឿង/គ្រួសារ | ២៥០គ្រឿង | ពេញមួយឆ្នាំ |
| សំណាញ់ | វង់ | ១០ | ១វង់/គ្រួសារ | ១០វង់ | ខែមករា ដល់ ឧសភា |
| សន្ទូច | ផ្លែ | ៥០ | ១០០ផ្លែ/គ្រួសារ | ៥០,០០០ផ្លែ | ពេញមួយឆ្នាំ |
| អួនអូសដៃ | វង់ | ៦ | ១វង់គ្រួសារ | ៦វង់ | ខែមីនា ដល់ ខែមេសា |
| ជនរុញដៃ | គ្រឿង | ៣ | ១គ្រឿង/គ្រួសារ | ៣គ្រឿង | ខែកុម្ភៈ ដល់ ខែមីនា |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីន | ១៧៤គ្រឿង | ២០០-១០០០គីឡូក្រាម | ៦សេស-១៨សេស |
| ទូកអុំ និងចែវ | ០៣គ្រឿង | ៥០-១៥០គីឡូក្រាម | |

- ឧបករណ៍នេសាទនិងទូកកាណូតរបស់អ្នកនៅក្នុងតំបន់ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទ ៖

| ប្រភេទ ឧបករណ៍ | ឯកតា | ចំនួនគ្រួសារ | ចំនួនឧបករណ៍ នេសាទ | ទំហំ/ប្រវែង (សរុប) | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| មងរាយ | ដៃ(១ដៃ=៨០ម) | ២០ | ២ដៃ/គ្រួសារ=១៦០ម | ៣២០០ម | ពេញមួយឆ្នាំ |
| លបឫស្សី | គ្រឿង | ០៣ | ៣០គ្រឿង/គ្រួសារ | ៩០គ្រឿង | ពេញមួយឆ្នាំ |
| សំណាញ់ | វង់ | ០៥ | ១វង់/គ្រួសារ | ០៥វង់ | ខែមករា ដល់ ឧសភា |
| សន្ទូច | ផ្លែ | ១០ | ១០០ផ្លែ/គ្រួសារ | ១,០០០ផ្លែ | ពេញមួយឆ្នាំ |
| អួនអូសដៃ | វង់ | ០៥ | ១វង់គ្រួសារ | ០៥វង់ | ខែមីនា ដល់ ខែមេសា |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីន | ១៥៥គ្រឿង | ២០០-១០០០គីឡូក្រាម | ៦សេស-១៨សេស |
| ទូកអុំ និងចែវ | ០៥គ្រឿង | ១០០-២០០គីឡូក្រាម | |

- ឧបករណ៍នេសាទ និងទូកកាណូតរបស់អ្នកមិនមែនជាសមាជិកសហគមន៍ដែលមកពីខាងក្រៅសហគមន៍៖

| ប្រភេទឧបករណ៍ | ឯកតា | ចំនួនគ្រួសារ | ចំនួនឧបករណ៍នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| មងរាយ | ដៃ(១ដៃ=៨០ម) | ២០ | ១០ដៃ/គ្រួសារ=៨០០ម | ១៦០០០ម | ពេញមួយឆ្នាំ |
| លបឫស្សី | គ្រឿង | ៣០ | ៥០គ្រឿង/គ្រួសារ | ១៥០០គ្រឿង | ពេញមួយឆ្នាំ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីន | ៣០គ្រឿង | ៣០០-១.០០០គីឡូក្រាម | ៦សេស-១៨សេស |

គ. ការប៉ាន់ប្រមាណផលចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ (គិតជា គក) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រីចំរុះ | ៨០០គីឡូក្រាម | ៣៦០គីឡូក្រាម | ១១៦០គីឡូក្រាម |
| លៀស | | | |
| ខ្យង | | | |
| ........... | | | |
| .......... | | | |

## ៥-ផែនការគ្រប់គ្រងសហគមន៍នេសាទ

### ក. ទស្សនៈវិស័យ ៖

សហគមន៍នេសាទពោធិ៍កន្រ្ទៃសែនជ័យ មានទស្សនៈវិស័យចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយសមធម៌ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។

### ខ. គោលបំណង ៖

- ចូលរួមគ្រប់គ្រងដែននេសាទទឹកសាបដែលបានលុបពីឡូត៍នេសាទ កន្លែងនេសាទគ្រួសារដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬ សហគមន៍ធ្វើនេសាទ កន្លែងនេសាទបំរុង ទំនាបលិចទឹកក្នុងរដូវតំឡើង នាទីព្រៃលិចទឹក
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តភាព និងធានាការបែងចែកផលប្រយោជន៍ ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍ តាមរយៈការអភិវឌ្ឍន៍ចម្រុះដោយមានការចូលរួម
- ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ ហើយនិងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់លើធនធានធម្មជាតិ ។

### គ. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### គ.១ ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺរៀបចំឡើងដោយគិតគូរអំពីប្រភេទដែន

នេសាទ ប្រភេទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេង |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន (ក្នុងពេលតែមួយ) | |
| -បឹងបាក់អង្រុត ១៥ហិកតា -បឹងខ្លាខាំគោ ១០,៨ហិកតា -បឹងរលំធំពាក់កណ្តាល ៩ហិកតា -បឹងសាច់ខ្មៅ ៨ហិកតា | មករាដល់ធ្នូ | មងរាយ | ៨០ម/គ្រួសារ | ៥០គ្រួសារ | សមាជិកសហគមន៍និងមិនសមាជិកសហគមន៍ |
| | តុលាដល់មករា | លបឫស្សី | ១០គ្រឿង/គ្រួសារ | ២០គ្រួសារ | សមាជិកសហគមន៍និងមិនសមាជិកសហគមន៍ |
| | ពេញមួយឆ្នាំ | សំណាញ់ | មិនកំណត់ | មិនកំណត់ | សមាជិកសហគមន៍និងមិនសមាជិកសហគមន៍ |
| | មិថុនាដល់ធ្នូ | សន្ទូច | ៣០០ផ្លែ/គ្រួសារ | ៥០គ្រួសារ | សមាជិកសហគមន៍និងមិនសមាជិកសហគមន៍ |
| | មីនាដល់មេសា | អួនអូសដៃ | ១វង់/គ្រួសារ | ៥គ្រួសារ | សមាជិកសហគមន៍និងមិនសមាជិកសហគមន៍ |
| | មិថុនាដល់កញ្ញា | លាន់ | ៣០គ្រឿង/គ្រួសា | ១០គ្រួសារ | សមាជិកសហគមន៍និងមិនសមាជិកសហគមន៍ |
| -បឹងប្រយ៉ាប ៤ហត -បឹងជីមាំង ៣,៥ហត -បឹងខ្លាយរាំង ២,១ហិកតា -បឹងរលំ២ហិកតា -បឹងលាដើង ១ហិកតា -បឹងជីវ័ន្ត ១ហិកតា -បឹងរលំតូច ១ហិកតា | មករាដល់ធ្នូ | មងរាយ | ៨០ម/គ្រួសារ | ២៥គ្រួសារ | សមាជិកសហគមន៍និងមិនសមាជិកសហគមន៍ |
| | តុលាដល់មករា | លបឫស្សី | ១០គ្រឿង/គ្រួសារ | ១០គ្រួសារ | សមាជិកសហគមន៍និងមិនសមាជិកសហគមន៍ |
| | ពេញមួយឆ្នាំ | សំណាញ់ | មិនកំណត់ | មិនកំណត់ | សមាជិកសហគមន៍និងមិនសមាជិកសហគមន៍ |
| | មិថុនាដល់ធ្នូ | សន្ទូច | ៣០០ផ្លែ/គ្រួសារ | ៣០គ្រួសារ | សមាជិកសហគមន៍និងមិនសមាជិកសហគមន៍ |
| | មីនាដល់មេសា | អួនអូសដៃ | ១វង់/គ្រួសារ | ៣គ្រួសារ | សមាជិកសហគមន៍និងមិនសមាជិកសហគមន៍ |
| | មិថុនាដល់កញ្ញា | លាន់ | ១០គ្រឿង/គ្រួសារ | ៨គ្រួសារ | សមាជិកសហគមន៍និងមិនសមាជិកសហគមន៍ |
| (**បឹងមានទំហំតូចជាង១ហិកតា**) | កក្កដាដល់កុម្ភៈ | មងរាយ | ៥០ម/គ្រួសារ | ១៥គ្រួសារ | សមាជិកសហគមន៍និងមិនសមាជិកសហគមន៍ |

| | | | | | |
|---|---|---|---|---|---|
| -បឹងខ្សែដែក<br>-បឹងរាំង១ដើម<br>-បឹងខ្សែកន្ទ្រប<br>-បឹងសត្វចងក<br>-បឹងប្រឡាក់ក្របី<br>-បឹងថ្លុកតាគង់<br>-បឹងត្រីរស់<br>-បឹងខ្សាច់<br>-បឹងព្រៃកក្រពើ<br>-បឹងផ្ទោល<br>-បឹងផ្កាយ<br>-បឹងខ្មៅ<br>(ក្នុងបឹងនីមួយៗ) | **សីហា ដល់ មករា** | លបឫស្សី | ៤គ្រឿង/គ្រួសារ | ៨គ្រួសារ | សមាជិកសហគមន៍និង<br>មិនសមាជិកសហគមន៍ |
| | ពេញមួយឆ្នាំ | សំណាញ់ | មិនកំណត់ | មិនកំណត់ | សមាជិកសហគមន៍និង<br>មិនសមាជិកសហគមន៍ |
| | កក្កដាដល់ធ្នូ | សន្ទូច | ១០០ផ្លែ/គ្រួសារ | ១៥គ្រួសារ | សមាជិកសហគមន៍និង<br>មិនសមាជិកសហគមន៍ |
| | កក្កដាដល់វិច្ឆិកា | អួនអូសដៃ | ១វង់/គ្រួសារ | ២គ្រួសារ | សមាជិកសហគមន៍និង<br>មិនសមាជិកសហគមន៍ |
| -ព្រៃកសត្វចងក<br>-ព្រៃកក្រពើ<br>-ព្រៃកកោះចាប<br>-ព្រៃកអូរទទឹង<br>-ព្រៃកតាឃ្លេ<br>-ព្រៃកពាមទន្លា | | | | | សមាជិកសហគមន៍និង<br>មិនសមាជិកសហគមន៍ |
| | | | | | សមាជិកសហគមន៍និង<br>មិនសមាជិកសហគមន៍ |
| | | | | | សមាជិកសហគមន៍និង<br>មិនសមាជិកសហគមន៍ |
| | | | | | សមាជិកសហគមន៍និង<br>មិនសមាជិកសហគមន៍ |
| | | | | | សមាជិកសហគមន៍និង<br>មិនសមាជិកសហគមន៍ |
| -អូរព្រៃកគោករទេះ<br>-អូរខ្មោចពីរ<br>-អូរឡាក់កំភ្លាញ<br>-អូរខ្សែដែក<br>-អូរពាមតាឡឹង<br>-អូរតាគង់<br>-អូរតាគុត<br>-អូរខ្នងខ្លាយ<br>-អូរកោះយាយមាស<br>-អូរកោះបាយក្រៀម<br>-អូរបឹងខ្សាច់ | | | | | សមាជិកសហគមន៍និង<br>មិនសមាជិកសហគមន៍ |
| | | | | | សមាជិកសហគមន៍និង<br>មិនសមាជិកសហគមន៍ |
| | | | | | សមាជិកសហគមន៍និង<br>មិនសមាជិកសហគមន៍ |
| | | | | | សមាជិកសហគមន៍និង<br>មិនសមាជិកសហគមន៍ |
| | | | | | សមាជិកសហគមន៍និង<br>មិនសមាជិកសហគមន៍ |

| | | | | | |
|---|---|---|---|---|---|
| -អូរយាយអ៊ីង<br>-អូរបាក់ខែង | | | | | |

**គ.២ ផែនការកែលម្អកន្លែងនេសាទសហគមន៍**

ផែនការកែលម្អដែននេសាទត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម៖

| ដែននេសាទ | ទំហំ | ទំហំដែលត្រូវកែលម្អ | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម - បញ្ចប់ |
|---|---|---|---|---|---|
| បឹងជីមាំង | ៣,៥ ហិកតា | ១ហិកតា | ស្វែងរកម្ចាស់ជំនួយ (ធ្វើគម្រោងស្នើសុំ) | ១០០ | ២០១៧ - ២០១៩ |
| | | | ប្រជុំផ្សព្វផ្សាយ | ១០០ | ២០១៧ - ២០១៩ |
| | | | គ្រឿងចក្រស្តារឡើងវិញ | ពិភាក្សាជាក់ស្តែង គិតជាម៉ែត្រគូប ឬគិតជាម៉ោង ១ម៉ែត្រគូបថ្លៃ =............... ១ម៉ោងថ្លៃ =............. សរុបទាំងអស់ប៉ុន្មាន........... ម៉ែត្រគូប ឬប៉ុន្មាន......... ម៉ោង | ២០១៧ - ២០២០ |

**គ.៣ ផែនការកំណត់និងរៀបចំកន្លែងអភិរក្ស**

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស នឹងត្រូវរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោម៖

| ឈ្មោះដែននេសាទ | ទំហំ(ហ.ត) ត្រូវអភិរក្ស | ប្រភេទនៃការអភិរក្ស | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| បឹងបាក់អង្រុត ១៨ហិកតា | ១៨ហិកតា | ត្រីមេពូជ ព្រៃលិចទឹក | ទប់ទំនប់ត្រង់កន្លែងគងប បឹងបាកក់អង្រុតធ្វើកន្លែងអភិរក្ស<br>-បណ្តោយ១០ម<br>-ខ្នងលើ(ទទឹងទំនប់)៨ម<br>-កំពស់៤ម<br>-ជើងទេ១០ | ពិភាក្សាជាក់ស្តែង | .............. | .............. |

| | | | | | | |
|---|---|---|---|---|---|---|
| | | | -ដាក់លូ មុខកាត់ ១ម បណ្តោយ១ម ចំនួន ១០កង់ | | | |
| | | | ផ្សព្វផ្សាយពីកន្លែងអភិរក្ស និងការហាមឃាត់ដល់ប្រជាពលរដ្ឋឱ្យបានទូលំទូលាយ (១ដង/ឆ្នាំសំរាប់រយៈពេល៣ឆ្នាំ) | ២០០ | ២០១៧ | ២០១៩ |
| | | | បោះបង្គោលព្រំតំបន់អភិរក្ស បង្គោលស៊ីម៉ង់៤បង្គោល | ១.២០០ | ២០១៧ | ២០១៧ |
| | | | ដាក់ស្លាកសញ្ញាចំនួន២ស្លាក | ៣៣០ | ២០១៧ | ២០១៧ |
| | | | ដាក់ជំរកសិប្បនិម្មិត(ជំរំឫស្សី (១០០មx១០០ម) | ១៥០០ | ២០១៨ | ២០១៩ |
| | | | សង់ប៉មយាមការពារកន្លែងអភិរក្សធ្វើពីបេតុងគ្រឿងដែកប្រក់ស័ង្កសី (៤មx៥មx៧ម) | ១៦.០០០.០០០៛ ៤.០០០ដុល្លា | ២០១៨ | ២០១៩ |
| | | | យាមល្បាតការពារកន្លែងអភិរក្ស | ២១៦០ (១ខែ=៦០$) | រយៈពេលបីឆ្នាំ | |

**គ.៤ ផែនការគ្រប់គ្រងព្រៃលិចទឹក**

ផែនការគ្រប់គ្រងព្រៃលិចទឹកត្រូវបានរៀបចំឡើងវិញ ដូចមាននៅក្នុងតារាងខាង ក្រោមៈ

| ឈ្មោះដែននេសាទ | ទំហំ (ហ.ត) | ប្រភេទព្រៃឈើត្រូវដាំ | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| -បឹងបាក់អង្រុត | -១០ហិកតា (១០០ម ជុំវិញបឹង) | ព្រៃលិចទឹក រាំង ត្រស់ ចង្កែង ទៀនព្រៃ | ប្រជុំផ្សព្វផ្សាយពីសារៈសំខាន់ព្រៃលិចទឹក ដល់ប្រជាពលរដ្ឋ | ៦០០.០០០៛ ១៥០ដុល្លា | ២០១៧ | ២០១៩ |
| | | | ស្វែងរកអ្នកជួយឧបត្ថម្ភតាមរយៈការសរសេរគម្រោងស្នើសុំ | ៤០០.០០០៛ ១០០ដុល្លា | | |
| | | | ដាំព្រៃលិចទឹក (១២៥០០ដើម) ចន្លោះ ៨ម៉ែត្រដាំ ១ដើម ១ដ=១៧០០៛ | ២១.០០០.០០០៛ ៥.៣១៣ដុល្លា | | |
| | | | បោះបង្គោលព្រំព្រៃលិចទឹកចំនួន៨ដើម | ៣.២០០.០០០៛ ៨០០ដុល្លា | ២០១៧ | ២០១៨ |
| | | | ស្លាកសញ្ញា៤ស្លាក ១ស្លាក=៥០០.០០០៛ | ២.០០០.០០០៛ ៥០០ដុល្លា | ២០១៧ | ២០១៩ |
| | | | យាមល្បាត | ៨.៦៤០.០០០៛ ២.១៦០ដុល្លា | ២០១៧ | ២០២៩ |

## គ៥-ផែនការទប់ស្កាត់បទល្មើសជលផល

ផែនការចុះទប់ស្កាត់បទល្មើសជលផលត្រូវបានរៀបចំដូចខាងក្រោម:

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ប្រជុំផ្សព្វផ្សាយ<br>-ផ្សព្វផ្សាយតាមមេក្រូ ៣ថ្ងៃ/ឆ្នាំ<br>-ផ្សព្វផ្សាយបិទឯកសារ១ដង/ឆ្នាំ<br>-ប្រជុំផ្សព្វផ្សាយ១ដង/ឆ្នាំ | -មានការយល់ដឹងពីការប្រើប្រាស់ឧបករណ៍នេសាទ និងសារៈសំខាន់នៃធនធានជលផល<br>-មានការយល់ដឹងពីការគ្រប់គ្រងសហគមន៍នេសាទ<br>-ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ថយចុះ | ១.២៦០ | គណៈកម្មការ សមាជិកស.ន អាជ្ញាធរមូលដ្ឋាន ជំនាញ | មេសា/រៀងរាល់ឆ្នាំ | |
| ប្រជុំពិភាក្សាគណៈកម្មការសហគមន៍រៀបចំផែនការប្រចាំឆមាស | -គណៈកម្មការទទួលបាននូវបទពិសោធន៍ល្អៗ<br>-មានផែនការសមស្របជាក់លាក់ដើម្បីចុះអនុវត្តការងារ | ១៦៥<br>(២ដង/ឆ្នាំ) | គណៈកម្មការ សមាជិកស.ន អាជ្ញាធរមូលដ្ឋាន អង្គភាពពាក់ព័ន្ធ | មករា និងមិថុនា/រៀងរាល់ឆ្នាំ | |
| អនុវត្តផែនការៈ<br>(រៀបចំកំលាំងចុះ បង្រ្កាបដល់ទីកន្លែងដោយទំនាក់ទំនង និងសហការជាមួយអាជ្ញាធរមូលដ្ឋាន អង្គភាពពាក់ព័ន្ធ និងអង្គការដៃគូ) | -បទល្មើសនេសាទថយចុះ និងឈានទៅលុបបំបាត់ទាំងស្រុង<br>-ធនធានជលផលកើនឡើង<br>-ជីវភាពសមាជិកស.នធូរធារ | ៧២០០<br>(១០០$/ដង)<br>រយៈពេល ៧២ដង សម្រាប់៣ឆ្នាំ | គណៈកម្មការ សមាជិកស.ន អាជ្ញាធរមូលដ្ឋាន ជំនាញជលផល ស្ថាប័នពាក់ព័ន្ធ | (២ដង/ខែ)<br>(រយៈពេលបីឆ្នាំ) | |
| ចុះល្បាតដោយសហការរវាងគណៈកម្មការសហគមន៍ និងអាជ្ញាធរមូលដ្ឋាន | -បទល្មើសនេសាទថយចុះ និងឈានទៅលុបបំបាត់ទាំងស្រុង<br>-ធនធានជលផលកើនឡើង<br>-ជីវភាពសមាជិកស.នធូរធារ | ៣៦០០<br>(២៥$/ដង)<br>រយៈពេល ១៤៤ដង សម្រាប់៣ឆ្នាំ | គណៈកម្មការ សមាជិកស.ន អាជ្ញាធរមូលដ្ឋាន | (៤ដង/ខែ)<br>(រយៈពេលបីឆ្នាំ) | |
| ល្បាតប្រចាំការ ២៤ម៉ោង | -បទល្មើសនេសាទថយចុះ និងឈានទៅលុបបំបាត់ទាំងស្រុង | ៥៤០០$<br>(៥$/ថ្ងៃ)<br>សម្រាប់រយៈពេល៣ឆ្នាំ | គណៈកម្មការ សមាជិកស.ន | រៀងរាល់ថ្ងៃ<br>(រយៈពេល៣ឆ្នាំ) | |
| មធ្យោបាយនិងសម្ភារៈ<br>-សាំង និងប្រេងបាត<br>-អាវភ្លៀង អាវពោង ពិល មួក | មានលទ្ធភាពចុះល្បាតដោយមានប្រសិទ្ធិភាព | ២.៣៤៦ | គណៈកម្មការ សមាជិកស.ន អាជ្ញាធរមូលដ្ឋាន | ២០១៧ | ២០១៩ |

| | | | | | |
|---|---|---|---|---|---|
| -កាតទូរស័ព្ទ អាយកូមទាក់ទង<br>-ម៉ាស៊ីនថត កែវយិត | | | ជំនាញជលផល<br>អង្គការ | | |
| ទិញទូកម៉ាស៊ីនថ្មីចំនួន២គ្រឿង ទំហំ បណ្តោ៩មxទទឹង១,២មx ជំរៅ០,៦ម | មានមធ្យោបាយចុះល្បាត | ២.៤០០ | គណៈកម្មការ សមាជិកស.ន អាជ្ញាធរមូលដ្ឋាន ជំនាញជលផល អង្គការ | ២០១៧ | |

## គ៦-ផែនការប្រជុំប្រចាំខែ និងសម្ភារៈអនុវត្តការងាររបស់គណៈកម្មការសហគមន៍នេសាទ

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ប្រជុំគណៈកម្មការសហគមន៍នេសាទ សប្តាហ៍ទី៣នៃខែ/រៀងរាល់ត្រីមាស | -របាយការណ៍លទ្ធផលសម្រេចបានក្នុងខែ<br>-មានផែនការណ៍អនុវត្តបន្ត | ៦៦០ | -គណៈកម្មការ<br>-ក្រុមល្បាត | ២០១៧ | ២០២០ |
| ប្រជុំជាមួយអាជ្ញាធរឃុំឬស្ថាប័នពាក់ព័ន្ធ (១០-២០/រៀងរាល់ខែ) | -ទទួលព័ត៌មាន និងផ្តល់របាយការណ៍លទ្ធផលសម្រេចបានក្នុងខែ<br>-បញ្ចូលផែនការណ៍ជាមួយផែនការអភិវឌ្ឍឃុំ | ៥៤០ | -អាជ្ញាធរឃុំ<br>-គណៈកម្មការ | ២០១៧ | ២០២០ |
| -សម្ភារៈការិយាល័យ<br>-ទិញក្រដាស់ ប៊ិច<br>-ព្រីនឯកសារ<br>-ការទំនាក់ទំនង | មានសម្ភារៈការិយាល័យសម្រាប់ប្រើប្រាស់ | ១៥០ | គណៈកម្មការ | រយៈពេល៣ឆ្នាំ | |

## គ៧-ផែនការផ្សព្វផ្សាយនិងបណ្តុះបណ្តាល

ផែនការផ្សព្វផ្សាយនិងបណ្តុះបណ្តាលត្រូវបានរៀបចំឡើងដើម្បីពង្រឹងសមត្ថភាពដល់សហគមន៍នេសាទ ដូចមានខាងក្រោម ៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ (ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ផែនការផ្សព្វផ្សាយ | | | | | |
| ប្រជុំផ្សព្វផ្សាយអំពីច្បាប់<br>-ជលផល ឯកសារគតិយុត្តិនានាដែលពាក់ព័ន្ធនឹងស.ន<br>-លក្ខន្តិកៈ<br>បទបញ្ជាផ្ទៃក្នុងស.ន | -សមាជិកសហគមន៍នេសាទ និងអ្នកខាងក្រៅមានការយល់ដឹង និងអនុវត្តតាម<br>-សមាជិកនិងប្រជាពលរដ្ឋចូលរួមអនុវត្តតាមផែនការ និងវិធាន | ១២០០ | គណៈកម្មការ,សមាជិកស.ននិងអ្នកក្រៅស.ន អាជ្ញាធរមូលដ្ឋាន ជំនាញជលផល, | -មករា/រៀងរាល់ឆ្នាំ រយៈពេល៣ឆ្នាំ ២០១៧-២០១៩ | |

| | | | | | |
|---|---|---|---|---|---|
| | ច្បាប់នានាដែលបានផ្សព្វផ្សាយ | | អង្គការដៃគូរ | | |
| បិទផ្សាយឯកសារ ១ដង/ឆ្នាំ | -ផលត្រីនៅក្នុងសហគមន៍មានការកើនឡើងប្រជាពលរដ្ឋអាចរកត្រីបានច្រើននាំឲ្យជីវភាពធូរធារ | ១៣០ | | ខែមករា (រាល់ឆ្នាំ) | ខែមករា (រាល់ឆ្នាំ) |
| -ចែកចាយឯកសារផែនការប្រើប្រាស់ឧបករណ៍ដល់អ្នកនេសាទ១ដង/ឆ្នាំ<br>-ចែកចាយឯកសារនានាផ្សព្វផ្សាយដែលត្រូវ | | ១៣០ | | មេសា (រាល់ឆ្នាំ) | មេសា (រាល់ឆ្នាំ) |
| ផែនការបណ្តុះបណ្តាល | | | | | |
| វគ្គបណ្តុះបណ្តាលពីរបៀបរៀបចំលិខិតរដ្ឋបាល :<br>-របាយការណ៍<br>-កំណត់ហេតុ<br>-គម្រោងស្នើសុំថវិកា<br>-គម្រោងថវិកានិងការគ្រប់គ្រងថវិកាស.ន | គណៈសហគមន៍នេសាទ សមាជិកស.ន ប្រជាពលរដ្ឋយល់ដឹង និងអាចអនុវត្តបានក្នុងការងារជាក់ស្តែង | ១២០០ | គណៈកម្មការនិងសមាជិកស.ន អាជ្ញាធរមូលដ្ឋាន សិស្ស,និស្សិត | ២០១៧ | ២០១៩ |
| វគ្គបណ្តុះបណ្តាលវិធីសាស្ត្រការប្រមូលព័ត៌មាន | គណៈកម្មការសហគមន៍នេសាទបានយល់ដឹងពីរបៀបយកព័ត៌មានផ្សេងៗពាក់ព័ន្ធការងារសហគមន៍ | ៥០០ | គណៈកម្មការ ស.ន | ២០១៧-២០១៩ | |
| វគ្គបណ្តុះបណ្តាលពីការសម្របសម្រួលដោះស្រាយទំនាស់ | កាត់បន្ថយទំនាស់ពីធំមកតូច គណៈកម្មការ សមាជិកសហគមន៍ និងប្រជាពលរដ្ឋមូលដ្ឋានទទួលបានដំណោះស្រាយសមស្របដោយសន្តិវិធីនិងគ្មានអំពើហឹង្សា | ៥០០ | គណៈកម្មការនិងសមាជិកស.ន ប្រជាពលរដ្ឋ អាជ្ញាធរមូលដ្ឋាន | ២០១៧-២០១៩ | |

## គ៨- ផែនការបង្កើនមុខរបរសមាជិកក្នុងសហគមន៍នេសាទ

ផែនការបង្កើនមុខរបរសមាជិកក្នុងសហគមន៍នេសាទត្រូវបានរៀបចំឡើងដូចខាងក្រោម៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ (ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ផែនការបណ្តុះបណ្តាល | | | | | |
| ចិញ្ចឹម (ត្រី កង្កែប អន្ទង់) | ចេះអំពីរបៀបចិញ្ចឹមនិង មានមុខរបរបង្កើនប្រាក់ចំណូល | ១.៥០០ | ជំនាញជលផល អង្គការដៃគូ គណៈកម្មការនិងសមាជិកស.ន | ២០១៧-២០១៩ | |

| | | | | |
|---|---|---|---|---|
| ចិញ្ចឹមសត្វ (មាន់ ទា ជ្រូក) | ចេះអំពីរបៀបចិញ្ចឹមនិង មានមុខរបរបង្កើនប្រាក់ចំណូល | ១.៥០០ | ជំនាញពេទ្យសត្វ អង្គការដៃគូ គណៈកម្មការនិង សមាជិកស.ន | ២០១៧-២០១៩ |
| កែច្នៃផលនេសាទ | មានមុខរបរបង្កើនប្រាក់ចំណូល | ១.៥០០ | ជំនាញជលផល អង្គការដៃគូ គណៈកម្មការនិង សមាជិកស.ន | ២០១៧-២០១៩ |
| កែច្នៃសម្ភារៈប្រើប្រាស់ពីកំប្លោក ស្លឹកត្នោត និងកក់ | មានមុខរបរបង្កើនប្រាក់ចំណូល | ១.៨០០ | អង្គការដៃគូ គណៈកម្មការនិង សមាជិកស.ន | ២០១៧-២០១៩ |
| ជំនាញវិជ្ជាជីវៈលើការផ្តល់សេវាទស្សនាកំសាន្ត | -ក្រុមចុងភៅ<br>-ក្រុមផ្ទះស្នាក់នៅ<br>-ក្រុមដឹកជញ្ជូន<br>-ក្រុមធ្វើរយានយន្ត<br>-ក្រុមផ្គត់ផ្គង់ផលិតផលកសិកម្ម<br>-ក្រុមរោងលម្ហែ (កញ្ចុះ) | ១.០០០ | អង្គការដៃគូ គណៈកម្មការនិង សមាជិស.ន | ២០១៧-២០១៩ |
| ទស្សនៈកិច្ចសិក្សា | | ២.៥០០ | អង្គការដៃគូ គណៈកម្មការនិង សមាជិស.ន | ២០១៧-២០១៩ |

**គ១០- ផែនការបង្កើតក្រុមសន្សំឥណទានដើម្បីបង្កើនមុខរបរ**

ផែនការបង្កើតក្រុមសន្សំឥណទានដើម្បីបង្កើនមុខរបរ ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ(ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ផ្សព្វផ្សាយ ជ្រើសរើសសមាជិកក្រុមសន្សំប្រាក់ | ក្រុមសន្សំប្រាក់ឥណទានសហគមន៍នេសាទ ត្រូវបានបង្កើតឡើង | ១០០ | គណៈកម្មការនិង សមាជិកស.ន | ២០១៧ | ២០១៧ |
| ប្រជុំរៀបចំគោលការណ៍ផ្ទៃក្នុងក្រុមសន្សំប្រាក់ | -មានលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមសន្សំប្រាក់<br>-មានដំណើរការល្អ (ខ្ចី សង) | ៥០០ | គណៈកម្មការនិង សមាជិកស.ន | ២០១៧ | ២០១៧ |
| ផ្តល់ប្រាក់កំចី និង ប្រមូលប្រាក់សន្សំ | មានទុនសម្រាប់ចាប់ផ្តើមមុខរបរ | ២០០០ | គណៈកម្មការនិង សមាជិកស.ន | ២០១៧ | ២០១៧ |
| ប្រជុំប្រចាំខែ | -របាយការណ៍សាច់ប្រាក់<br>-ការរីកចម្រើននូវមុខរបរ | ២៧០ | ក្រុមសន្សំ | ២០១៧ | ២០១៩ |

**គ៨-ផែនការអភិវឌ្ឍវារីវប្បកម្មក្នុងសហគមន៍**

ផែនការសម្រាប់អភិវឌ្ឍវារីវប្បកម្មក្នុងសហគមន៍ត្រូវបានរៀបចំឡើងដូចខាងក្រោម :

| ប្រភេទវារីវប្បកម្ម | ចំនួន | ប្រភេទកូនត្រីពូជ | បរិមាណកូនត្រីពូជ | ប៉ាន់ស្មានតម្លៃ(ដុល្លា) | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ ប្រមូលផល |
|---|---|---|---|---|---|---|

| | | | | | | |
|---|---|---|---|---|---|---|
| ចិញ្ចឹមត្រីតាមបែរ (២៣គ្រួសារ) | ២០ប:២,៥មx៣,៥មx២,៥ម | ត្រីឆ្ពោ | ៣៥០០ កូន/ឆ្នាំ | ១.០៥០.០០០៛ (១ក=៣០០៛) | ឧសភា/ ២០១៧ | ខែមីនា/ ២០១៩ |
| | ៣ប:៤មx៣មx២,៥ម | ត្រីប្រា | ៧២០ កូន/ឆ្នាំ | ២១៦.០០០៛ (១ក=៣០០៛) | ឧសភា/ ២០១៧ | ខែមីនា/ ២០១៩ |
| ចិញ្ចឹមត្រីតាមស្រះ (៨គ្រួសារ) | ៦ស:១៥មx១០មx២,៥ម | ត្រីអណ្តែង | ១៣៥០០ កូន/ឆ្នាំ | ២.៧០០.០០០៛ (១ក=២០០៛) | ខែឧសភា /២០១៧ | ខែតុលា/ ២០១៩ |
| | ២ស:១៥មx១០មx៣ម | ត្រីឆ្ពិន | ១៥០០ កូន/ឆ្នាំ | ៣០០.០០០៛ (១កូន=២០០៛) | ខែឧសភា /២០១៧ | ខែធ្នូ/ ២០១៧ |

**គ១១- ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទ**

ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | លទ្ធផលរំពឹងទុក | ប៉ាន់ប្រមាណតម្លៃ (ដុល្លា) | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| សាងសង់ស្នាក់ការសហគន៍នេសាទ ទំហំ៦មx៨ម សរសរបេតុងគ្រឿងឈើ ប្រក់ស័ង្កសី | - សហគមន៍នេសាទមានកន្លែងសម្រាប់ធ្វើការ | ៥០០០ | គណៈកម្មការសមាជិកស.ន ស្ថាប័នពាក់ព័ន្ធ អង្គការដៃគូ | ២០១៧ | ២០១៩ |
| សម្ភារ:សហគមន៍នេសាទ (តុ ទូ ក្តារខៀន កៅអី កំព្យូទ័រ ) | មានសម្ភារ:សម្រាប់ស.ន ធ្វើការ | ១០០០ | | ២០១៧ | ២០១៩ |

**គ១២-ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍**

ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ត្រូវបានរៀបចំឡើងដូចខាងក្រោម :

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ ចាប់បញ្ចប់ | ចំណូល ដុល្លា | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានសមាជិកភាពសហគមន៍នេសាទ | -ផ្សព្វផ្សាយការចូលជាសមាជិក និងបង់ប្រាក់សមាជិកភាព<br>-ប្រមូលភាគទាន ៥០០រៀល/ម្នាក់ | ២០១៧ | ២០១៩ | ២៤.២៥ | ៥០០រៀល/នាក់ (១៩៤នាក់) |
| ភាគទានប្រចាំឆ្នាំ | -ផ្សព្វផ្សាយជូនដំណឹងដល់សមាជិកបង់ប្រាក់ភាគទានប្រចាំឆ្នាំ<br>-ប្រមូលភាគទានប្រចាំឆ្នាំសមាជិកស.ន ៥.០០០ រៀល/ម្នាក់ | ២០១៧ | ២០១៩ | ២៤២,៥ | ៥.០០០រៀល/ម្នាក់ (១៩៤នាក់) |

| | | | | | |
|---|---|---|---|---|---|
| កម្រៃអ្នកនេសាទមិនមែនជាសមាជិកនិងអ្នកមកពីក្រៅ | ប្រមូលប្រាក់កម្រៃពី អ្នកនេសាទមិនមែនជាសមាជិកនិងអ្នកមកពីក្រៅ ១០.០០០រៀល/នាក់ | ២០១៧ | ២០១៩ | | |
| សរសេរគម្រោងស្នើសុំថវិកាពី<br>-រាជរដ្ឋាភិបាល<br>-សប្បុរសជន<br>-អង្គការដៃគូរពាក់ព័ន្ធ | -ទំនាក់ទំនងជាមួយរដ្ឋាភិបាល និងអង្គការដៃគូរ<br>-សរសេរគម្រោងស្នើសុំថវិកា<br>-តាមដាន | | | | |
| សរុប | | | | | |

## ឃ. ផែនការយុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំដូចខាងក្រោម ៖

- បង្កើតគណៈកម្មការសម្រាប់អនុវត្តតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនការ រួមមាន ៖ សមាជិកគណៈកម្មការសហគមន៍នេសាទចាស់ទុំ ដែលមានបទពិសោធន៍ និងចំណេះដឹងល្អៗ ជាពិសេសបញ្ហានេសាទ
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់ចំពោះផែនការណាដែលទាក់ទង និងបច្ចេកទេសជលផល ដូចជា ការធ្វើផែនការកន្លែងអភិរក្សមេពូជត្រី ការរៀបចំកន្លែង អភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រែក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី ការរកថវិកាទ្រទ្រង់ជាដើម
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោង និងម្ចាស់ជំនួយ ដើម្បីទទួលបានការឧបត្ថម្ភគាំទ្របច្ចេកទេសនិងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ
- រៀបចំផែនការអនុវត្តផែនការតាមដំណាក់កាលនីមួយៗដោយជាក់លាក់និងផែនការសកម្មភាពប្រចាំឆ្នាំ
- ទាក់ទងជាមួយរដ្ឋបាលជលផលនិងស្ថាប័នពាក់ព័ន្ធ ដើម្បីសុំការគាំទ្រថវិកា និងជួយរកដៃគូសម្រាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទនិងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីខាងក្រៅសហគមន៍
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ
- ធ្វើសមាហរណកម្មបញ្ចូលផែនការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍឃុំ
- រៀបចំធ្វើស្នាក់ការសហគមន៍នេសាទចំនួនមួយខ្នងនិងទិញទូកម៉ាស៊ីនចំនួន២គ្រឿងសម្រាប់គ្រប់គ្រងនិងថែរក្សាការពារកន្លែងនេសាទសហគមន៍ ។

## តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ពោធិ៍កុច្រីសែនជ័យរយៈពេល ៣ ឆ្នាំ (២០១៧-២០១៩)

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ (រៀល) | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ១.ការប្រើប្រាស់ឧបករណ៍នេសាទ | • ប្រជុំផ្សព្វផ្សាយការប្រើប្រាស់ឧបករណ៍នេសាទ | • សំបុត្រត្រីឡើងវិញ<br>• កាត់បន្ថយការប្រើប្រាស់ឧបករណ៍នេសាទល្មើសច្បាប់ | ៦០០.០០០៛<br>១៥០ដុល្លា | អង្គការដៃគូ | ខែ០១<br>រៀងរាល់ឆ្នាំ | ខែ០១<br>រៀងរាល់ឆ្នាំ | រៀងរាល់ឆ្នាំ |
| | • ត្រួតពិនិត្យនិងតាមដានលើការប្រើប្រាស់ឧបករណ៍នេសាទ | • សហគមន៍និងអ្នកនេសាទទាំងអស់អនុវត្តន៍តាមលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍នេសាទ | | | | | |
| ២.ផែនការកែលម្អកន្លែងនេសាទបឹងជីម៉ាំង ១ហិកតា | • ស្វែងរកម្ចាស់ជំនួយ | • បឹងទំហំ ១ហិកតាត្រូវបានស្តារអោយមានទឹកគ្រប់គ្រាន់ សម្រាប់ជាជម្រករបស់វារីសត្វ និងរុក្ខជាតិ | ៤០០.០០០៛<br>១០០ដុល្លា | អង្គការដៃគូ | ខែ០៣<br>រៀងរាល់ឆ្នាំ | ខែ០៣<br>រៀងរាល់ឆ្នាំ | |
| | • ប្រជុំផ្សព្វផ្សាយ | | ៤០០.០០០៛<br>១០០ដុល្លា | | | | |
| | • គ្រឿងចក្រស្តារបឹងឡើងវិញទំហំ១ហ.ត | | តម្លៃពិភាក្សាម្តងទៀត | | | | |
| ៣.ផែនការកំណត់ និងរៀបចំកន្លែងអភិរក្សបឹងបាក់អង្រុត ១៨ហិកតា | • ធ្វើទំនប់ទប់ទឹកត្រង់កន្លែង កដប នៅបឹងបាក់អង្រុតដើម្បីរក្សាទឹកទុកទាំងរដូវប្រាំងនិងរដូវវស្សា បណ្តោយ ១០ម៉ែត្រ ខ្នងលើ(ទទឹងទំនប់)៨ម៉ែត្រ កំពស់៤ម៉ែត្រ ជើងទេ១០ម៉ែត្រ ដោយមានដាក់លូសម្រាប់បើកមុខទឹក | • ប្រភេទត្រីពូជសំខាន់ៗត្រូវបានអភិរក្ស<br>• ប្រជាជនបានយល់ដឹងពីសារៈប្រយោជន៍កន្លែងអភិរក្ស<br>• កន្លែងអភិរក្សត្រូវបានរៀបចំឡើងនិងមានព្រំប្រទល់ច្បាស់លាស់ | តម្លៃពិភាក្សាម្តងទៀត | អង្គការដៃគូ | ២០១៧ | ២០១៩ | |
| | • ផ្សព្វផ្សាយអោយប្រជាពលរដ្ឋបានដឹងអំពីកន្លែងអភិរក្សដើម្បីចូលរួមថែរក្សា ការពារ | • មានទីជម្រកសម្រាប់យាមល្បាត<br>• បទល្មើសនេសាទត្រូវបានកាត់បន្ថយ | ៨០០.០០០៛<br>២០០ដុល្លា | -អង្គការដៃគូ<br>-ថវិកាបដិភាគរបស់សហគមន៍ | | | |
| | • បោះបង្គោលព្រំប្រទល់តំបន់អភិរក្ស បង្គោលស៊ីម៉ង់តិ៍ចំនួន៤បង្គោល | | ៤.៨០០.០០០៛<br>១.២០០ដុល្លា | អង្គការដៃគូ | ២០១៧ | ២០១៩ | |
| | • ដាក់ស្លាកសញ្ញាចំនួន២ស្លាក | | ១.៣២០.០០០៛<br>៣៣០ដុល្លា | អង្គការដៃគូ | ២០១៧ | ២០១៩ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | • ដាក់ជំរុំឬស្សីធ្វើជម្រកសិប្បនិម្មិត (១០០មx១០០ម) | | ៦.០០០.០០០៛<br>១៥០០ដុល្លា | អង្គការដៃគូ | ២០១៨ | ២០១៩ | |
| | • សង់ប៉មយាមការពារកន្លែងអភិរក្សធ្វើពីសរសរបេតុងគ្រឿងដែក ទំហំ(៤មx៥មx៧ម) | | ១៦.០០០.០០០៛<br>៤.០០០ដុល្លា | អង្គការដៃគូ | ២០១៧ | ២០១៩ | |
| | • យាមល្បាតកន្លែងអភិរក្ស (សម្រាប់រយៈពេល៣ឆ្នាំ) | | ៨.៦៤០.០០០៛<br>២.១៦០ដុល្លា | អង្គការដៃគូ | ២០១៧ | ២០១៩ | |
| ៤.ផែនការគ្រប់គ្រងនិងដាំព្រៃលិចទឹកបឹងបាក់អង្រុត ១០ហិកតា | • ប្រជុំផ្សព្វផ្សាយពីសារៈសំខាន់ព្រៃលិចទឹកដល់ប្រជាពលរដ្ឋ | • ប្រជាពលរដ្ឋយល់ដឹងពីសារៈសំខាន់ព្រៃលិចទឹក<br>• បង្កើនផលត្រី វារីសត្វគ្រប់ប្រភេទ<br>• មានជម្រកសម្រាប់ត្រីពងកូន<br>• ជួយថែរក្សាលំនឹងបរិស្ថានធម្មជាតិ | ៦០០.០០០៛<br>១៥០ដុល្លា | -អង្គការដៃគូ<br>-ថវិកាបដិភាគរបស់សហគមន៍ | ២០១៧ | ២០១៧ | |
| | • ស្វែងរកអ្នកជួយឧបត្ថម្ភ សរសេរគម្រោងស្នើសុំ | | ៤០០០០០៛<br>១០០ដុល្លា | | ២០១៧ | ២០១៧ | |
| | • ដាំព្រៃលិចទឹក(១២៥០០ដើម) ចន្លោះ៨មដាំ១ដើម ១ដើម=១៧០០៛ | | ២១.០០០.០០០៛<br>៥៣១៣ដុល្លា | | ២០១៧ | ២០១៩ | |
| | • បោះបង្គោល៨ដើម ១បង្គោល=៤០០.០០០៛ | | ៣.២០០.០០០៛<br>៨០០ដុល្លា | | ខែ០៤/២០១៨ | ខែ០៤/២០១៨ | |
| | • ដាក់ស្លាកសញ្ញាចំនួន៤ស្លាក ១ស្លាក=៥០០.០០០៛ | | ២.០០០.០០០៛<br>៥០០ដុល្លា | | ខែ០៥/២០១៨ | ខែ០៥/២០១៨ | |
| | • យាមល្បាត | | ៨.៦៤០.០០០៛<br>២.១៦០ដុល្លា | | ២០១៧ | ២០១៩ | |
| ៥.ផែនការទប់ស្កាត់បទល្មើសនេសាទ | ប្រជុំផ្សព្វផ្សាយអំពីផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងច្បាប់ស្តីជលផល<br>-ផ្សព្វផ្សាយតាមមេក្រូ ៣ថ្ងៃ/ឆ្នាំ<br>-ផ្សព្វផ្សាយបិទឯកសារ១ដង/ឆ្នាំ<br>-ប្រជុំផ្សព្វផ្សាយ១ដង/ឆ្នាំ | -មានការយល់ដឹងពីការប្រើប្រាស់ឧបករណ៍នេសាទ និងសារៈសំខាន់នៃធនធានជលផល<br>-មានការយល់ដឹងពីការគ្រប់គ្រងសហគមន៍នេសាទ<br>-ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ថយចុះ | ៥.០៤០.០០០៛<br>១.២៦០ដុល្លា | អង្គការដៃគូ<br>អាជ្ញាធរឃុំ ជំនាញ | ខែមេសា រៀងរាល់ឆ្នាំ(៣ឆ្នាំ) ពីឆ្នាំ២០១៧ ដល់ ឆ្នាំ២០១៩ | | |
| | ប្រជុំពិភាក្សាគណៈកម្មការ | -គណៈកម្មការទទួលបាន | ៦៦០.០០០៛ | អង្គការដៃគូ | មករា និង មិថុនារៀងរាល់ឆ្នាំ | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | សហគមន៍រៀបចំផែនការប្រចាំមាស | នូវបទពិសោធន៍ល្អៗ<br>-មានផែនការសមស្រប<br>ជាក់លាក់ដើម្បីចុះអនុវត្ត ការងារ | ១៦៥ដុល្លា | | | | |
| | អនុវត្តផែនការៈ<br>(រៀបចំកំលាំងចុះ បង្ក្រាបដល់ទីកន្លែងដោយទំនាក់ទំនង និង សហការជាមួយអាជ្ញាធរមូល ដ្ឋាន អង្គភាពពាក់ព័ន្ធ និងអង្គការដៃគូ) | -បទល្មើសនេសាទថយចុះ និងឈានទៅលុបបំបាត់ ទាំងស្រុង<br>-ធនធានជលផលកើនឡើង<br>-ជីវភាពសមាជិកស.នធូរធារ | ២៨.៣៦០.០០០៛<br>៧.២០០ដុល្លា<br>៧២ដង<br>រយៈពេល៣ឆ្នាំ | អង្គការដៃគូ | ២០១៧ | ២០១៩ | |
| | ចុះល្បាតសហការរវាងគណៈកម្មការសហគមន៍ជាមួយអាជ្ញាធរមូលដ្ឋាន | -បទល្មើសនេសាទថយចុះ និងឈានទៅលុបបំបាត់ ទាំងស្រុង<br>-ធនធានជលផលកើនឡើង<br>-ជីវភាពសមាជិកស.នធូរធារ | ១៤.៤០០.០០០៛<br>២៥$/ដង<br>៣៦០០ដុល្លា | អង្គការដៃគូ | ៤ដង/ខែ(រយៈពេល៣ឆ្នាំ) | | |
| | មធ្យោបាយនិងសម្ភារៈ<br>-សាំង និងប្រេងបាត<br>-អាវភ្លៀង អាវពោង ពិល មួក<br>-កាតទូរស័ព្ទ អាយកូមទាក់ទង<br>-ម៉ាស៊ីនថត កែវយិត | ចុះល្បាតដោយមានប្រសិទ្ធិភាព | ២.៣៤៦ដុល្លា | អង្គការដៃគូ | ២០១៧ | ២០១៩ | |
| | ទិញទូកម៉ាស៊ីនថ្មីចំនួន០២គ្រឿង | មានមធ្យោបាយចុះល្បាត | ២.៣០០ដុល្លា | អង្គការដៃគូ | ២០១៧ | ២០១៩ | |
| **៦.ផែនការបណ្តុះបណ្តាល** | វគ្គបណ្តុះបណ្តាលពីរបៀប រៀបចំលិខិតរដ្ឋបាល :<br>-សរសេរបាយការណ៍<br>-ធ្វើកំណត់ហេតុ<br>-គម្រោងស្នើសុំថវិកា<br>-គម្រោងថវិកានិងការគ្រប់គ្រងថវិកាស.ន | គណៈសហគមន៍នេសាទ សមាជិកស.ន ប្រជាពលរដ្ឋ សិស្ស និស្សិតបានយល់ដឹង និងអាចអនុវត្តបាន ក្នុងការងារជាក់ស្តែង | ៥.៦០០.០០០៛<br>១.៤០០ដុល្លា | | | | |
| | វគ្គបណ្តុះបណ្តាលពីកំព្យូទ័រ | គណៈសហគមន៍នេសាទ(៣នាក់) | ៣១៥ | អង្គការដៃគូ | ២០១៧ | ២០១៩ | |
| | វគ្គបណ្តុះបណ្តាលពីៈ<br>-ការគ្រប់គ្រងនិងសារៈសំខាន់នៃធនធានធម្មជាតិ | គណៈសហគមន៍នេសាទ សមាជិកស.ន ប្រជាពលរដ្ឋ សិស្ស និស្សិតបានយល់ដឹង | ២.០០០.០០០៛<br>៥០០ដុល្លា | អង្គការដៃគូ | ២០១៧ | ២០១៩ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | -សិទ្ធិជាមូលដ្ឋានលើ ធនធានធម្មជាតិ | និងអាចអនុវត្តបាន<br>ក្នុងការងារជាក់ស្តែង | | | | | |
| | វគ្គបណ្តុះបណ្តាលវិធីសាស្ត្រការប្រមូលព័ត៌មាន | គណៈកម្មការសហគមន៍នេសាទបានយល់ដឹង និងអាចអនុវត្តបានក្នុងការងារជាក់ស្តែង | ១.៦០០.០០០៛<br>៤០០ដុល្លា | អង្គការដៃគូ | ២០១៧ | ២០១៩ | |
| | វគ្គបណ្តុះបណ្តាលពីការសម្របសម្រួក ដោះស្រាយ ទំនាស់ | គណៈសហគមន៍នេសាទ សមាជិកស.នបានយល់ដឹង និងអាចអនុវត្តបាន<br>ក្នុងការងារជាក់ស្តែង | ២.០០០.០០០៛<br>៥០០ដុល្លា | អង្គការដៃគូ | ២០១៧ | ២០១៩ | |
| គ៧. ផែនការបង្កើនមុខរបរសមាជិកសហគមន៍នេសាទតាមរយៈបណ្តុះបណ្តាលនិងការអនុវត្តជាក់ស្តែង | ចិញ្ចឹមត្រី | •មានមុខរបរបង្កើនប្រាក់ចំណូល | ៦.០០០.០០០៛<br>១៥០០ដុល្លា | អង្គការដៃគូ | ២០១៧ | ២០១៩ | |
| | ចិញ្ចឹមសត្វ (មាន់ ទា ជ្រូក) | •មានមុខរបរបង្កើនប្រាក់ចំណូល | ៦.០០០.០០០៛<br>១៥០០ដុល្លា | អង្គការដៃគូ | ២០១៧ | ២០១៩ | |
| | ទស្សនៈកិច្ចសិក្សា | •សហគមន៍នឹងទទួលបានបទពិសោធន៍ល្អៗ | ១០.០០០.០០០៛<br>២.៥០០ដុល្លា | អង្គការដៃគូ | ២០១៧ | ២០១៩ | |
| | ក្រុមកែច្នៃផលិតផលជលផល | •គណៈសហគមន៍និងសមាជិកនេសាទបង្កើតឡើងជាក់ស្តែង<br>•មានផលិតផលជលផលផ្គត់ផ្គង់ដល់តំបន់ទស្សនាកំសាន្តនិងទីផ្សារ<br>•មានមុខរបរបង្កើនប្រាក់ចំណូល | ៦.០០០.០០០៛<br>១៥០០ដុល្លា | អង្គការដៃគូ | ២០១៧ | ២០១៩ | |
| | ក្រុមដាំបន្លែ | •គណៈសហគមន៍និងសមាជិកនេសាទបង្កើតឡើងជាក់ស្តែង<br>•មានបន្លែផ្គត់ផ្គង់ដល់តំបន់ទស្សនាកំសាន្ត និងទីផ្សារ<br>•មានមុខរបរបង្កើនប្រាក់ចំណូល | ២.០០០.០០០៛<br>៥០០ដុល្លា | អង្គការដៃគូ | ២០១៧ | ២០១៩ | |
| ៨.ផែនការអភិវឌ្ឍន៍វារីវប្បកម្មចិញ្ចឹមត្រីតាមស្រះ | • រៀបចំស្រះ រកកូនត្រីដាក់ចិញ្ចឹមថែទាំ | • កូនត្រីប្រា ត្រីឆ្កិនចំនួន១០០០០កូន និងត្រូវផ្តល់ចំនួន៥គ្រួសារ<br>• រកប្រាក់ចំណូលជួយលើកស្ទួយ | ២.០០០.០០០៛<br>៥០០ដុល្លា | អង្គការដៃគូ | ២០១៧ | ២០១៩ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | សេដ្ឋកិច្ចគ្រួសារ<br>• កាត់បន្ថយការធ្វើនេសាទត្រីពីធម្មជាតិ | | | | | |
| **៩.ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទ** | សាងសង់ស្នាក់ការសហគន៍នេសាទ ទំហំ៣មx៥ម ធ្វើអំពីបេតុងគ្រឿងឈើ ប្រក់ស័ង្កសី | • សហគមន៍នេសាទមានការិយាល័យសម្រាប់ធ្វើការ<br>• មានលទ្ធភាពពេញលេញក្នុងការការពារ គ្រប់គ្រង កន្លែងនេសាទសហគមន៍ | ៨.០០០.០០០៛<br>២.០០០ដុល្លា | អង្គការដៃគូ | ២០១៧ | ២០១៩ | |
| | សម្ភារៈសហគមន៍នេសាទ<br>(តុ ទូ ក្ដារខៀន កៅអី កំព្យូទ័រ) | • មានសម្ភារៈសម្រាប់ស.ន ធ្វើការ | ៣.៦០០.០០០៛<br>៩០០ដុល្លា | អង្គការដៃគូ | ២០១៧ | ២០១៩ | |
| **១០.ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍** | -ផ្សព្វផ្សាយការចូលជាសមាជិក និងបង់ប្រាក់សមាជិកភាព<br>-ប្រមូលភាគទាន ៥០០រៀល/ម្នាក់ | • ថវិកាដែលបានមកពីសមាជិក អ្នកមិនមែនជាសមាជិកសហគមន៍ អ្នកមកពីខាងក្រៅនិងជំនួយមកពីរាជរដ្ឋាភិបាល អង្គការដៃគូនានា នឹងត្រូវបានប្រើប្រាស់ សម្រាប់ដំណើរការអភិវឌ្ឍន៍សហគមន៍នេសាទ | ២៦៥.០០០៛<br>៦៦.២៥ដុល្លា | សមាជិកសហគមន៍ | ២០១៧ | ២០១៩ | |
| | -ផ្សព្វផ្សាយជូនដំណឹងដល់សមាជិកបង់ប្រាក់ភាគទានប្រចាំឆ្នាំ<br>-ប្រមូលភាគទានប្រចាំ ២០០០៛/ឆ្នាំ | | ៣.១៨០.០០០៛<br>៧៩៥ដុល្លា | សមាជិកសហគមន៍ | ២០១៧ | ២០១៩ | |
| | ថវិកាសម្រាប់ប្រើប្រាស់ក្នុងសហគមន៍បានពីការប្រាក់ដើមចំនួន៥០០០$ ដាក់ក្នុងធនាគារ (ជំនួយពីអង្គការ CI) | | ចំណូល ១០៨០ដុល្លា រយៈពេល៣ឆ្នាំ | អង្គការ CI | ២០១៧ | ២០១៩ | |
| | ថវិកាសម្រាប់ប្រើប្រាស់ក្នុងសហគមន៍បានពីការប្រាក់ដើមចំនួន៣០០០$ តាមរយៈក្រុមសន្សំ (ជំនួយពីអង្គការ CI) | | ចំណូល ៣៦០ដុល្លា រយៈពេល៣ឆ្នាំ | អង្គការ CI | ២០១៧ | ២០១៩ | |
| | • ប្រមូលថវិកាមកពីខាងក្រៅសហគមន៍ ១០.០០០៛/ម្នាក់ | | | | | | |

| សកម្មភាព | កាលបរិច្ឆេទ | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៧ | | | | | | | | | | | | ២០១៨ | | | ២០១៩ | | |
| | មករា | កុម្ភៈ | មិនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | មករា | .... | ធ្នូ | មករា | ... | ធ្នូ |
| ១. ការប្រើប្រាស់ឧបករណ៍នេសាទ | | | | | | | | | | | | | | | | | | |
| ២.ការកែលំអកន្លែងនេសាទសហគមន៍ | | | | | | | | | | | | | | | | | | |
| ៣.ការកំណត់ និងរៀបចំកន្លែងអភិរក្ស | | | | | | | | | | | | | | | | | | |
| ៤.ផែនការគ្រប់គ្រងព្រៃលិចទឹក | | | | | | | | | | | | | | | | | | |
| ៥.ផែនការទប់ស្កាត់បទល្មើសជលផល | | | | | | | | | | | | | | | | | | |
| ៦.ផែនការប្រជុំប្រចាំខែនិងទិញសម្ភារៈការិយាល័យ | | | | | | | | | | | | | | | | | | |
| ៧. ផែនការផ្សព្វផ្សាយ និងបណ្តុះបណ្តាល | | | | | | | | | | | | | | | | | | |
| ៨.ផែនការបង្កើតមុខរបរសមាជិកសហគមន៍នេសាទ | | | | | | | | | | | | | | | | | | |
| ៩.ផែនការបង្កើតកន្លែងទស្សនាកំសាន្តក្នុងស.ន | | | | | | | | | | | | | | | | | | |
| ១០.ផែនការបង្កើតក្រុមសន្សំប្រាក់ដើម្បីផ្លាស់ប្តូរ | | | | | | | | | | | | | | | | | | |
| ១១.ផែនការសាងសង់ស្នាក់ការសហគមន៍នេសាទ | | | | | | | | | | | | | | | | | | |
| ១២.ផែនការអភិវឌ្ឍវារីវប្បកម្ម | | | | | | | | | | | | | | | | | | |
| ១៣.ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍសហគមន៍ | | | | | | | | | | | | | | | | | | |

សូមគោរពជូន
លោកមេឃុំ
ដើម្បីជូនពិនិត្យ និង សម្រួល"
......ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៧
**ប្រធានគណៈកម្មការសហគមន៍នេសាទ**
**ពោធិ៍ក្រទីសែនជ័យ**

លេខ......
បានឃើញ និង គោរពជូន
លោកនាយសង្កាត់រដ្ឋបាលជលផលកំពង់លែង
"ដើម្បីជូនពិនិត្យនិងសម្រួល"
......ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៧
**មេឃុំពោធិ៍**

បានឃើញ និង គោរពជូន
លោកនាយផ្នែករដ្ឋបាលជលផលផ្សារឆ្នាំង
"ដើម្បីជូនពិនិត្យ និង សម្រួល"
......ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៧
**នាយសង្កាត់រដ្ឋបាលជលផលកំពង់លែង**

លេខ......
បានឃើញ និង គោរពជូន
លោកនាយខណ្ឌរដ្ឋបាលជលផលកំពង់ឆ្នាំង
"ដើម្បីជូនពិនិត្យ និង សម្រួល"
......ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧
**នាយផ្នែករដ្ឋបាលជលផលផ្សាររឆ្នាំង**

លេខ......
បានឃើញ និង គោរពជូន
លោកនាយអធិការដ្ឋានរដ្ឋបាលជលផលខាងត្បូងទន្លេសាប
"ដើម្បីជូនពិនិត្យ និង សម្រួល"
......ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៧......
**នាយខណ្ឌរដ្ឋបាលជលផលកំពង់ឆ្នាំង**

លេខ......
បានឃើញ និង គោរពជូន
ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា
ប្រធានរដ្ឋបាលជលផល
"ដើម្បីជូនពិនិត្យ និង សម្រេចដោយអនុគ្រោះ"
......ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៧......
**នាយអធិការដ្ឋានរដ្ឋបាលជលផលខាងត្បូងបឹងទន្លេសាប**

លេខ.........ជផ
បានឃើញ និង ឯកភាព
រាជធានីភ្នំពេញ ថ្ងៃទី...... ខែសីហា ឆ្នាំ២០១៧
**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**
**ប្រធានរដ្ឋបាលជលផល**

**ទេ ព ជាសាន**